BMI0138

# សម្ភាសន៍ជាមួយ ឡាច ជឿ ភេទប្រុស អាយុ៦០ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័តទំនប់ត្រពាំងថ្ម

## រស់នៅភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ

## ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៤៧:១៥

## ២៣ទំព័រ

វណ្ណៈ : ថ្ងៃនេះថ្ងៃទី១៥ ខែ៦ ឆ្នាំ២០១១ ហើយខ្ញុំនេះឈ្មោះ សុខវណ្ណៈមកពីអង្គការ មជ្ឈមណ្ឌលឯកសារកម្ពុជាណាមីងណា ។

ជឿ : ចាស ។

វណ្ណៈ : ហើយខ្ញុំមកដល់ភូមិឃុំនេះដោយចង់ដឹងពីប្រវត្តរឿងបងប្អូនយើងដែលរស់នៅក្នុងសម័យខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ណាមីងណា ។ តើជួបការលំបាកអីខ្លះហើយបងប្អូនយើងបានផ្លាស់ទីលំនៅទៅខាងណាខ្លះ ហើយជួបធ្វើការងារអ្វីខ្លះ ហើយជាពិសេសនៅអាងត្រពាំងថ្មនេះគឺធ្វើឲ្យប្រជាជនស្លាប់ច្រើន ហើយការលើកទំនប់គឺមានដាក់កម្រិតដាក់ម៉ែត្រឲ្យធ្វើម្នាក់ៗដាក់អញ្ចឹងណាមីងណា ។

ជឿ : ចាស! ដាក់ម៉ែត្រគីប ។

វណ្ណៈ : បាទ! អញ្ចឹងបទសម្ភាសន៍របស់ខ្ញុំជាមួយមីងក្នុងថ្ងៃនេះ គឺខ្ញុំចង់បទសម្ភាសន៍របស់មីងទុកចងក្រងជាឯកសារប្រវត្តិសាស្រ្ត តើមីងយល់យ៉ាងម៉េចដែរ?

ជឿ : អត់អីទេ ។

វណ្ណៈ : បាទ! អត់អីទេ ។ អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង តើមីងឈ្មោះអីទៅ?

ជឿ : ឡាច ជឿ ។

វណ្ណៈ : ឡាច ជឿ?

ជឿ : ចាស ។

វណ្ណៈ : មីងអត់មានឈ្មោះក្រៅទៀតទេ?

ជឿ : អត់ទេ ។

វណ្ណៈ ៖ អាយុប៉ុន្មានហើយមីងសព្វថ្ងៃ?

ជឿ ៖ សព្វថ្ងៃ៦០ហើយ ។

វណ្ណៈ ៖ ៦០ហើយ ។ ប្ដីឈ្មោះអី?

ជឿ ៖ កុយ រ៉ន ។

វណ្ណៈ ៖ កុយ រ៉ន ។ គាត់អាយុប៉ុន្មានហើយ?

ជឿ ៖ ៦១ ។

វណ្ណៈ ៖ ៦១ ។ មានកូនប៉ុន្មានកូន?

ជឿ ៖ កូនមានពីរនាក់ ។

វណ្ណៈ ៖ តែពីរនាក់ទេ ។ ស្រីទាំងពីរ?

ជឿ ៖ ប្រុសទាំងពីរ ។

វណ្ណៈ ៖ អ៊ូ! ប្រុសទាំងពីរ ។ ស្រុកកំណើតពីដើមមីងនៅភូមិណា?

ជឿ ៖ ភូមិនេះឯង ភូមិប៉ោយក្ដឿង ។

វណ្ណៈ ៖ ភូមិ ប៉ោយក្ដឿង ។ ឃុំ?

ជឿ ៖ ឃុំព្រះនេត្រព្រះ ។

រ៉ន ៖ រាល់ថ្ងៃគេដាក់ស្រុកបន្ទាយមានជ័យ ។

វណ្ណៈ ៖ ពីដើមគេដាក់ស្រុកអីគេដែរ កាលជំនាន់ លន់ នល់?

ជឿ ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

វណ្ណៈ ៖ ខេត្ត?

ជឿ ៖ ពីដើមៗគេដាក់ខេត្តអយ?

រ៉ន ៖ ខេត្តបាត់ដំបង ។

ជឿ ៖ ខេត្តបាត់ដំបង ។

វណ្ណៈ ៖ បាទ! ឥឡូវភូមិឃុំស្រុកណ្ដុំមកខាងខេត្តបន្ទាយមានន័យវិញ?

ជឿ ៖ ចាស ។

វណ្ណៈ ៖ បាទៗ! ឪពុកមីងឈ្មោះអីដែរឪពុក?

ជឿ ៖ ឈ្មោះ តា សិញ ។

វណ្ណៈ ៖ អត់ស្គាល់ត្រកូលគាត់ទេ?

ជឿ ៖ អត់នេះ ឡាច សិញ ។

វណ្ណៈ ៖ ម្ដាយ?

ជឿ ៖ ប្ដីជីតា ជីតាណា?

វណ្ណៈ ៖ បាទ ។

ជឿ ៖ ពៅ ។

វណ្ណៈ ៖ ពៅអីទៅ?

ជឿ ៖ មិនដែលស្គាល់ឪគាត់ផង (សើច) ។

វណ្ណៈ ៖ អូរ! ម្ដាយឈ្មោះហ៊ា?

ជឿ ៖ ចាស! ម្ដាយឈ្មោះ ពៅ ។

វណ្ណៈ ៖ ពៅ! សព្វថ្ងៃគាត់ស្លាប់អស់ហើយ?

ជឿ ៖ ស្លាប់អស់ហើយតាំងពីខ្ញុំឆ្នាំតូចៗ ។

វណ្ណៈ ៖ ជំនាន់ណា?

ជឿ ៖ សម័យ លន់ នល់ ។

វណ្ណៈ ៖ អូរ! លន់ នល់ ទាំងអស់ហ្នឹង?

ជឿ ៖ ចាស ។

វណ្ណៈ ៖ បងប្អូនមានប៉ុន្មានបងប្អូន?

ជឿ ៖ បងប្អូនបង្កើតមាន៥នាក់ ។

វណ្ណៈ ៖ ៥មាននាក់ ។ មីងកូនទីប៉ុន្មាន?

ជឿ ៖ បងគេ ។

វណ្ណៈ ៖ កាលពីតូចបានរៀនសូត្រទេ?

ជឿ ៖ ខ្ញុំមិនបានរៀនទេ ។

វណ្ណៈ ៖ មិនបានរៀនទាល់តែសោះ?

ជឿ ៖ ចាស ។

វណ្ណៈ ៖ ហេតុអីបានមិនបានរៀន?

ជឿ ៖ ម៉ែឪអាល័យតែគ្រ អាល័យតែឃ្វាលក្របី សម័យពីដើមអាល័យតែក្រមានរៀនអីលោកគ្រូអើយ ។

វណ្ណៈ ៖ នៅឃ្វាលក្របីរហូត?

ជឿ ៖ ខ្លាចគ្រូវៃសម័យនោះ (សើច) ។

វណ្ណៈ : ខ្វាចគ្រូវៃ?

ជឿ : មិនហ៊ានទៅរៀនទេខ្លាចគ្រូវៃពីដើមមិញ ។

វណ្ណៈ : ហើយខ្លាចគ្រូវៃ ហើយឪពុកម្ដាយក្រដដក៏អត់ទៅរៀន ។

ជឿ : ចាស! ក្រ អត់ទៅបណ្ដោយ ។

វណ្ណៈ : ចុះមានបងប្អូនប្រុសៗគាត់ឲ្យទៅរៀនខ្លះទេ?

ជឿ : រៀន! ពួកប្អូនៗខ្ញុំរៀន អត់ៗតែខ្ញុំពីរនាក់ ប្អូនខ្ញុំ ។

វណ្ណៈ : អញ្ចឹងកាលសម័យសង្គ្រាមរដ្ឋប្រហារហើយ មីងធ្វើអីកាលហ្នឹង?

ជឿ : ចាស សម័យដែលប៉ុលពតហើយ?

វណ្ណៈ : អត់ទេ! សម័យ លន់ នល់ សម័យ សម្ដេច សីហនុ ។

ជឿ : ខ្ញុំធ្វើតែស្រែ ម៉ែឪធ្វើស្រែខ្ញុំក៏ធ្វើតែស្រែ ។

វណ្ណៈ : ធ្វើស្រែមើលក្របី?

ជឿ : ចាស ។

វណ្ណៈ : ដល់ពេលមានសង្គ្រាមឆ្នាំ៧១-៧២ខ្មែរក្រហមវៃជាមួយខាង លន់ នល់ អញ្ចឹងមានទម្លាក់គ្រាប់បែកមានអញ្ចឹងមានដឹងទេកាលហ្នឹង?

ជឿ : ដឹង! ដែលគេចូលវៃគេចូលវៃស្រុកនេះឯង ។

វណ្ណៈ : អញ្ចឹង ។

ជឿ : ដែលខ្មែរក្រហមចូលវៃ វៃស្រុកនេះឯង ។

វណ្ណៈ : មីងមានចូលរំដោះក្នុងព្រៃ ក្នុងអីណុងគេទេ?

ជឿ : អត់ទេ ។

វណ្ណៈ : អត់ទេ?

ជឿ : គ្រាន់តែវាចូលវៃមួយព្រូ រួចវាចេញ ។

វណ្ណៈ : ចុះនេះមានទម្លាក់គ្រាប់បែកទេភូមិនេះ?

ជឿ : អត់គ្រាន់តែវាចូលបាញ់ គ្រាន់តែចូលបាញ់ ។

វណ្ណៈ : លន់ នល់ ចូលបាញ់ទាហានខ្មែរក្រហម?

ជឿ : ខ្មែរក្រហមវាចូលមក ។

វណ្ណៈ : ខ្មែរក្រហមចូលមកបាញ់ទាហាន លន់ នល់?

ជឿ : ចាស ។

វណ្ណៈ : ចូលចេញចូល?

ជឿ : ចាស ។

វណ្ណៈ : អញ្ចឹងប្រជាជនមានគ្រោះថ្នាក់ទេ?

ជឿ : មានផាប់ខ្លះ ផាប់មួយភូមិនេះ ផាប់អស់ពីរនាក់ បាក់ជើង ។

វណ្ណៈ : អញ្ចឹង! មានសង្គ្រាមអញ្ចឹងមានពិបាកធ្វើស្រែ ធ្វើចំការទេ?

ជឿ : ពិបាកធ្វើ មានសង្គ្រាមពិបាកធ្វើចំការ តែគ្រាន់តែវាចូលវៃម៉ាព្រូទៅ វាចេញទៅបាត់ យើងក៏ធ្វើស្រែទៅ ។

វណ្ណៈ : បាទ! មានពួយន្តហោះមកទេ?

ជឿ : វាអត់ដែលមកទេ គ្រាន់តែប៉ុល ពត វៃ មួយស្រូវវាចេញទៅវិញហើយ ។

វណ្ណៈ : អញ្ចឹងពេលខ្មែរក្រហម កាន់កាប់នៅឆ្នាំ៧៥ នៅសម័យប៉ុលពតហ្នឹង គេមានជម្លៀសមីង ចេញពីភូមិនេះទេ?

ជឿ : ជម្លៀសទៅនៅភ្នំកូនថ្មី នៅស្រេះ ដាក់ជំរុំស្រេះ ។

វ៉ន : ចាក់សម្លាប់នៅស្រេះ ។

ជឿ : សម្លាប់ច្រើនណាស់ សម្លាប់នៅស្រេះលោកគ្រូអើយ ។

វណ្ណៈ : ៧៥ហ្នឹង?

ជឿ : ចាស ។

វណ្ណៈ : ម៉េចបានគេសម្លាប់?

ជឿ : សម្លាប់! បើកូនក្មេងអញ្ចេះសម្លាប់ម៉ែ ចង់ម៉ែទុក កូនក្មេងបោះបាន ដាក់ជំពុះទង់ពី ក្រោម ។

វណ្ណៈ : អញ្ចឹងទៀត?

ជឿ : ដាក់ជំពុះទង់ពីក្រោម ។

វណ្ណៈ : ពួកណាសម្លាប់?

ជឿ : ខ្មែរក្រហម ។

វ៉ន : មិនដឹងពួកណា បើយើងមិនស្គាល់គេ ។

ជឿ : យើងមិនស្គាល់ បើយើងខ្លាចគេឡើងរួច គ្រាន់តែមាសប្រាក់អីប្រមូលយកអស់លោក គ្រូ ។

វណ្ណៈ : អញ្ចឹងជំនាន់ខ្មែរក្រហមហើយ?

ជឿ ៖ ចាស ។

វណ្ណៈ ៖ អញ្ចឹងមានតែខ្មែរក្រហមទេ ព្រោះទាហាន លន់ នល់ ចាញ់ហើយកាលហ្នឹង ។

វ៉ន ៖ ទាហាន លន់ នល់ ចាញ់ ។

ជឿ ៖ ចាស! ទាហាន លន់ នល់ ចាញ់ ។

វណ្ណៈ ៖ អញ្ចឹង! មិញជម្លៀសទៅភូមិអី?

ជឿ ៖ នៅភូមិស្រេះ ។

វណ្ណៈ ៖ ភូមិស្រេះនោះនៅឆ្ងាយពីនេះទេ?

ជឿ ៖ នៅតាណោះ ។

វណ្ណៈ ៖ ជិតនេះដែរ?

ជឿ ៖ ណោះ ។

វណ្ណៈ ៖ ប្រហែលប៉ុន្មានគីឡូពីនេះ?

វ៉ន ៖ ប្រហែល៤-៥គីឡូ ។

ជឿ ៖ ៥គីឡូ ។

វ៉ន ៖ ចេញពីព្រះនេត្រព្រះទៅ ។

វណ្ណៈ ៖ ជម្លៀសចេញពីនេះទៅច្រើន យូរទៅ?

វ៉ន ៖ នៅមួយឆ្នាំ ។

ជឿ ៖ នៅមួយឆ្នាំបានគេឲ្យចូលធ្វើស្រែ ។

វណ្ណៈ ៖ ចុះមីងមិញបានដឹងថា គេស្រាវជ្រាវសម្លាប់ទាហាន?

ជឿ ៖ ចុះឈ្មោះណាលោកគ្រូ វាចូលមកវាថា បើអ្នកណាធ្វើការអី គេឲ្យទៅវិញកន្លែងវិញ ។

វ៉ន ៖ គេសួរថា ចង់ធ្វើធំណាស់ ។

ជឿ ៖ ដូចយើងធ្វើការអី ដូចលោកគ្រូថា ធ្វើមេទាហានក៏ប្រាប់គេត្រង់ថា ធ្វើមេទាហាន យើងមានស្អីខ្លះមានម៉ូតូ មានស្អីៗ យើងចុះ រួចវាស្រាវជ្រាវបញ្ជីវានេះឯង ថាឈ្មោះណាៗ រួចវាស្រាវជ្រាវថា ឈ្មោះណាៗ បានវាយកយើងទៅវៃចោល ដូចយើងឆោត

វ៉ន ៖ យើង សក្ក័៥ សក្ក័៦ គេសួរអញ្ចឹងឯង ។

ជឿ ៖ សួរដេញយើង យើងក៏ប្រាប់គេត្រង់ ។

វណ្ណៈ ៖ ក្នុងឆ្នាំ៧៥ហ្នឹង?

ជឿ ៖ ចាស! ពេលប៉ុលពតទើបចូលហ្នឹង វាវៃចប់ ។

វណ្ណៈ : ចុះមីងសកម្មភាពទាំងអស់ហ្នឹង តើមីងបានឃើញផ្ទាល់ភ្នែកឬក៏យ៉ាងម៉េច ឬគ្រាន់តែឮគេថាគេចាប់ទេឬក៏អត់បានឃើញគេវៃដែរទេ?

ជឿ : ឃើញ! ឃើញគេចាប់ចងនៅមុខផ្ទះចាប់ចង ខ្ញុំដើរខ្ញុំមិនទាំងហ៊ានមើលផង ខ្ញុំដើរអោនមិនហ៊ានមើល គ្រាន់តែគ្នាកំបុតដៃក៏ចាប់គ្នាចងដែរ ។

វណ្ណៈ : ជាពិសេសទាហាន លន់ នល់ ហ្នឹង ត្រូវស្លាប់?

ជឿ : ចាស! ទាហាន លន់ នល់ ត្រូវស្លាប់ ។

វណ្ណៈ : ចុះមន្ត្រីរាជការអី អ្នកធ្វើការមន្ត្រីរាជការ?

ជឿ : អត់មានទេ ។

វណ្ណៈ : អត់ទាល់ទេ?

ជឿ : មានតែពួកគេទេ យើងអត់ហ៊ានហើបក្បាលទេ ។

វណ្ណៈ : អញ្ចឹងទាហានខ្មែរក្រហមប្រកាសថា អ្នកណាធ្វើការអីគេឲ្យធ្វើវិញ?

ជឿ : ចាស ។

វណ្ណៈ : ដល់ពេលហើយបានស្រាវជ្រាវយកទៅសម្លាប់ហ្នឹង?

ជឿ : ចាស ។

វណ្ណៈ : គេចាប់យកទៅសម្លាប់នៅខាងណា?

ជឿ : គេមើលឈ្មោះគេហៅយើង ។

វណ្ណៈ : យកទៅដាក់គុកនៅឯណា?

ជឿ : លោកគ្រូអើយនេះខាងលិច ក្បាលខ្មោចឡើងរន្ធក ចាសៗដុតសុទ្ធតែក្បាលខ្មោច ។

វណ្ណៈ : អញ្ចឹង៧៥នោះក៏មានសម្លាប់មនុស្សហើយ សម្លាប់ពួកទាហានដែរអញ្ចឹងហា?

ជឿ : សម្លាប់ពួកទាហាន ។

វណ្ណៈ : ពួកណាពួកយោធាខ្មែរក្រហម?

ជឿ : មិនដែលស្គាល់គេ មិនហ៊ានដេញគេ ពួកប្រជាជនខ្លាចគេចង់ងាប់ ។

វណ្ណៈ : កាលនោះអត់ទាល់ស្គាល់អត់ទាល់អីទេ?

ជឿ : ចាស ។

វ៉ន : គេប្រាប់ថាគេយោធាៗ ។

វណ្ណៈ : បាទ! ពេលដែលសម្លាប់ហ្នឹងតើមីងមានស្គាល់ ពួកអ្នកដែលខ្មែរក្រហមចងយកទៅមីងមានស្គាល់គេដែរ?

ជឿ ៖ អត់ទេ ។

វណ្ណៈ ៖ មិនស្គាល់ទេ?

ជឿ ៖ ចាស! មិនស្គាល់ទេ បើគេមកពីឆ្ងាយ ដូចថាប្រធានចាស់គេដូរចោល គេវៃចោលអស់ប្រធានចាស់ ។

រ៉ន ៖ អូនអើយសម័យនោះ គ្រាន់អឺតមើលមុខគេ ខ្លាចឡើងញ័រ

ជឿ ៖ ឃើញចបអញ្ចេះ យើងដើរតាមផ្លូវមិនហ៊ានមើលផង គេមិនឲ្យយើងមើលខ្លាចឡើងញ័រ ។

វណ្ណៈ ៖ មីងទៅនៅស្រុះមួយឆ្នាំនោះ មីងធ្វើការងារអីខ្លះ?

ជឿ ៖ ធ្វើស្រែ ដកស្ទូង ដាំដំឡូង គេឲ្យដាំ ឲ្យយើងធ្វើទៅ ។

វណ្ណៈ ៖ ថ្មីៗ៧៥ភ្លាមមិនទាន់ពួកភ្នំពេញជម្លៀសមកទេ ពួក១៧មេសា មិនទាន់ជម្លៀសមកទេ?

ជឿ ៖ មិនទាន់មកទេ ។

វណ្ណៈ ៖ នៅទេ?

ជឿ ៖ ចាស ។

វណ្ណៈ ៖ ប៉ុន្តែពួកខ្មែរក្រហមបានបោសសំអាតពួកនៅក្នុងស្រុកសិន?

ជឿ ៖ ចាស ។

វណ្ណៈ ៖ ដែលជាប់និន្នាការទាហានអី?

ជឿ ៖ ចាស ។ ទាល់តែគេឲ្យចូលភូមិទើបឃើញពួកនេះ ពួកភ្នំពេញមក ។

វណ្ណៈ ៖ អញ្ចឹង៧៦បានចូលភូមិវិញ?

រ៉ន ៖ ដល់នេះគេមកបានគេជម្រះប្រធានភូមិ ប្រធាននេះអីជម្រះអស់ មកពីភ្នំពេញជម្រះផ្សេងនិរតីជម្រះផ្សេង យើងមិនដែលឃើញទេ គ្រាន់តែឃើញខ្លាចឡើងរួញ ។

ជឿ ៖ មិនហ៊ានទាំងមើលមុខចំផងលោកគ្រូ ។

វណ្ណៈ ៖ អ្នក១៧មេសាមកនៅក្នុងភូមិនេះច្រើនទេ?

ជឿ ៖ ច្រើនណាស់ ។

វណ្ណៈ ៖ ប្រហែលប៉ុន្មានទៅ?

រ៉ន ៖ គ្រប់ឃុំ ។

ជឿ ៖ នៅគ្រប់ឃុំដូចថាដាក់នៅនេះខ្លះ ភូមិប៉ោក្លឿនេះខ្លះទៅ ដាក់គ្រប់ឃុំមួយឃុំមួយឡានៗ ។

វណ្ណៈ ៖ អញ្ចឹងគណៈឃុំអ្នកណាគេ?

ជឿ ៖ ចាស?

វណ្ណៈ :	គណៈឃុំអ្នកណាគេ តាអីមិញ?

ជឿ :	តាក្រក ។

វណ្ណៈ :	ហ្នឹងហើយតាក្រក, ចុះមុនតាក្រកមានទេ?

វ៉ន :	ក្រោយតាក្រកបានមាន ។

វណ្ណៈ :	ក្រោយចាប់តាក្រកទៅពីណា?

ជឿ :	ក្រោយតាក្រក តាផន ។

វណ្ណៈ :	ចាប់តាក្រក ចូលតាផន?

ជឿ :	ចាស ។

វណ្ណៈ :	តាផនគេ?

ជឿ :	តាផន គេអត់វៃទេ គេជម្លៀសរត់ទៅភ្នំកូនខ្វែង ។

វណ្ណៈ :	គាត់រត់?

ជឿ :	រត់! បរទេះរត់ណាចេញពីភូមិណា ដល់ឃួនវៃចូលដល់សៀមរាបក្តឹងៗ បានពួកវាដកចេញអស់ ។

វណ្ណៈ :	តាផននោះមកពីខាងណា?

ជឿ :	តាផននេះមកពីខាងណា?

វ៉ន :	សៀមរាប ។

វណ្ណៈ :	នរតីហើយ?

ជឿ :	អត់និរតីទេ ខ្មែរយើងនេះឯង ។

វណ្ណៈ :	ដល់ក្រោយមកទៀត ក្រែលពួកនិរតីចូលមកទៀតភូមិនេះ?

ជឿ :	ចាស! និរតីចូលមកកាន់ ។

វណ្ណៈ :	ចូលមកកាន់ឈ្មោះអីទៅនិរតី?

ជឿ :	មិនដឹងឈ្មោះអីទេ ។

វ៉ន :	ឈ្មោះ គគីរមួយ អាទៀតឈ្មោះអីទេ មិនសូវគេច្បាស់លាស់ផង

ជឿ :	គគីរ ប្រធាននិរតី ។

វណ្ណៈ :	ប្រធានឃុំហ្អ?

ជឿ :	វាប្រធាននិរតី ។

វណ្ណៈ :	អញ្ចឹងគណៈស្រុកគណៈអីអត់ស្គាល់ទេ?

ជឿ :	អត់ដឹងអស់ទេ

វ៉ន :	អ្នកណាក៏ស៊ើបគេ ។

វណ្ណៈ :	អញ្ចឹងយាយថែមយាយអីអត់ស្គាល់ទៀតទេ?

ជឿ :	យាយថែមឃើញគាត់មកម្តងៗ ខ្ញុំទៅធ្វើការនៅទំនប់ឃើញគាត់ទៅម្តងៗ ជួនកាលគាត់មកមើលគាត់ទៅវិញទៅ យាយថែមទាបកាតិៗ ។

វណ្ណៈ :	បាទ! គាត់ទាប មុខស្រដៀងមីងដែរហ្នឹង ។

ជឿ :	ហ្នឹងហើយគាត់ទាប ។

វណ្ណៈ :	ទាប

វ៉ន :	ពួកនៅទំនប់ដែលឃើញ

ជឿ :	គាត់ទៅតំនប់បានខ្ញុំស្គាល់ ។

វណ្ណៈ :	បាទ! ហើយគាត់កាចទេ?

ជឿ :	ពុតែគេថាកាចៗ គាត់មិនដែលឃើញថាឲ្យប្រជាជន ធ្វើការរួចទៅវិញ ។

អ្នកភូមិ :	ស្លាប់ច្រើន ។

ជឿ :	ឪមីនេះឃើញទេ ទាហានប៉ុន្មានថ្ងៃ ស្លាប់សម័យប៉ុលពត ។

វណ្ណៈ :	អញ្ចឹងពេលចូលមកដល់ភូមិពេលឆ្នាំ១៩៧៩ តើនៅក្នុងភូមិនោះគេចាត់ចែងឲ្យមីងធ្វើអីទៀត?

ជឿ :	ធ្វើចំការ ស្ទូងស្រូវ បបរលោកគ្រូអើយសុទ្ធតែទឹក ខ្ញុំមិនដឹងយកមកធ្វើអី ខ្ញុំចាក់ចោលតាមផ្លូវ ប្រធានគេហៅមកកសាង (សើច) មិនដឹងយកមកធ្វើអីទឹកទទេ ។

វណ្ណៈ :	សុទ្ធទឹកហ្អ?

ជឿ :	បបរសុទ្ធតែទឹក ម្នាក់មួយវែក ។

វណ្ណៈ :	អញ្ចឹងមានអ្នកស្លាប់ដោយសារអត់អាហារទេ?

ជឿ :	អូរ.....ស្លាប់ច្រើនណាស់លោកគ្រូអើយ អ្នកថ្មីដែលគ្នាមិនធ្លាប់អត់ឃ្លាន ស្លាប់ច្រើនណាស់អ្នកថ្មី គ្រាន់តែសំបកដំឡូងវាទៅរើសសំបកដំឡូងស៊ីណា ។

វ៉ន :	គ្រាន់តែដំឡូងមីប៉ុននេះគេឲ្យមួយដីណា ដំឡូងមីមួយដុំ កាលនោះមានដំឡូងលក់ អត់ ។

ជឿ :	យើងស្រុកស្រែ យើងអត់យើងឃ្លានយើងចេះតែទ្រាំទៅ ដល់អ្នកថ្មីវាមិនដែលអត់ឃ្លានអីវាស្គមធំតែក្បាល ។

វ៉ន :	គ្នាមិនហ៊ានរក ។

ជឿ : គ្នាមិនហ៊ានរក ។

រ៉ន : គ្នាប្រជាជនថ្មីមក ។

វណ្ណៈ : ពេលដែល៧៦មកក្នុងភូមិគេឲ្យ ដកស្ទូង ធ្វើស្រែ ឲ្យហូបមិនគ្រប់គ្រាន់?

ជឿ : ដំឡូងមីប្រវែងនេះលោកគ្រូអើយ ឲ្យស៊ីមួយថ្ងៃ នាំគ្នាសម្ងៃតែត្រកួននិងអំពិលស៊ី ។

វណ្ណៈ : បាទ! អញ្ចឹងហូបដំឡូងរស់ដែរ?

ជឿ : យី! រស់មិនរស់ក៏ត្រូវតែហូប ស៊ីតែដំឡូងនិងបន្លែ រស់មិនរស់ក៏ត្រូវតែហូប ។

វណ្ណៈ : បាទ! អញ្ចឹងដូចថាមិនមានអ្នកណាតវ៉ាបានទេ បើដូចអ្នក១៧មេសាគ្នាមកនៅជាមួយគេ អញ្ចឹងអត់មានចំណី ចំណុកអីផ្សេងផ្សេងរំដូចគេដូចអ្នកស្រុកអ្នកភូមិ អ្នកស្រុកអ្នកភូមិអាច ទៅគាស់គល់ចេក បេះបន្លែបេះអីហូបអី អីបានតទៅទៀត?

ជឿ : នេះគល់ចេកម៉ែខ្ញុំហើយ មួយថ្ងៃៗអន្ទុយហានតែគល់ចេក មកពីធ្វើការអន្ទុយហានតែគល់ ចេកស៊ី ។

វណ្ណៈ : អញ្ចឹង ។

ជឿ : គល់ចេកដើមល្ហុង ដាំបាយ ។

វណ្ណៈ : អញ្ចឹងកាលណុងមីងរៀបការតាំងពីឆ្នាំណា?

ជឿ : ខ្ញុំបើវគ្គសម័យអាពត ។

វណ្ណៈ : សម័យអាពត?

ជឿ : ចាស ។

រ៉ន : ៧៨ ។

ជឿ : ខ្មែរក្រហម ។

វណ្ណៈ : ៧៨! អញ្ចឹងយើងអាចជ្រើសរើសស្រឡាញ់គ្នាឬក៏?

ជឿ : ម៉ែឪ ។

វណ្ណៈ : មានម៉ែឪ?

ជឿ : ចាស! ម៉ែឪសួរ ។

វណ្ណៈ : សួរ! អញ្ចឹងស្នើអង្គការទៅ?

ជឿ : ចាស! ស្នើអង្គការ ។

វណ្ណៈ : អញ្ចឹងយើងពេញចិត្តដែរ?

ជឿ : ចាស ។

វណ្ណៈ : កាលនោះមានបន្ទុំមានអីទេ?

ជឿ : មានបន្ទុំទេ ។

វណ្ណៈ : ពេញចិត្តដែរ?

ជឿ : អត់មានបន្ទុំយើងទេ ស្រឡាញ់ពេញចិត្តយើង ។

វណ្ណៈ : ការកាលហ្នឹងគ្មានភ្ញៀវ គ្មានអាចារ្យ គ្មានលោកទេ?

ជឿ : មានអី តែកកដៃអញ្ចេះឯង ។

វ៉ន : ចាប់ដៃ មានអីស៊ី មកស៊ីបបរតែមួយចាន ។

វណ្ណៈ :

មីងធ្វើការនៅនេះហើយគេមានបញ្ជូនមីងទៅណាទៀតបើមីងមាន...អីកាលនោះមីងការ ៧៨ ហើយ ចុះ៧៧អីធ្វើការនៅឯណា?

ជឿ : ធ្វើការ គេប្រើទៅលើកទំនប់លើកអី ។

វ៉ន : ខ្ញុំឡើងត្នោត ។

ជឿ : ខ្ញុំការហើយបានធ្វើទេ នៅធ្វើចំការធ្វើអីនៅនេះតិចៗ ។

វណ្ណៈ : ចុះថា ទៅលើកអាងត្រពាំងថ្ម?

ជឿ : កាលពីនៅក្រមុំ ។

វណ្ណៈ : ចុះឆ្នាំណាអាងត្រពាំងថ្មនោះគិត បើលើកតាំងពីក្រមុំ?

ជឿ : តាំងពីខ្មែរក្រហមចូលបានមួយឆ្នាំ យើងត្រូវលើក ។

វណ្ណៈ : តាំងពី៧៦មក?

ជឿ : ចាស ។

វណ្ណៈ : ៧៦-៧៧-៧៨ បែក?

ជឿ : ចាស ។

វណ្ណៈ : លើកប៉ុន្មានឆ្នាំបានហើយ?

ជឿ : ៣ឆ្នាំចាស ចេះតែលើកៗទៅណា ។

វណ្ណៈ : ៧៦-៧៧-៧៨?

ជឿ : ចាស ។ ដល់តែនេះរើសប្រជាជនរួច គេរើសកងចល័តដាក់ទៅរើសទៀត ។

វណ្ណៈ : អញ្ចឹងកាលនោះដោយសារតែមីងអត់ទាន់មានគ្រួសារបានគេរើសទៅដាក់កងចល័ត ពីណាអ្នកមកហៅមីងចូលកងចល័ត?

ជឿ :	ប្រធានគេ ។

វណ្ណៈ :	ប្រធានឈ្មោះអីគេ?

ជឿ :	ប្រធានគេ តាក្រក ប្រធានគេគ្រប់គ្រងខាងទំនប់ ។

វណ្ណៈ :	ពេលមីងទៅដល់អាងត្រពាំងថ្ម ឃើញមានមនុស្សច្រើនយ៉ាងម៉េច ហើយស្ថានភាពការយ៉ាងម៉េច?

ជឿ :	មនុស្សច្រើនណាស់លោកគ្រូអើយ មួយសន្ធាត់ទាំងអស់ ។

វណ្ណៈ :	ទាំងអស់ប្រហែលជាប៉ុន្មានទៅ ច្រើននោះ?

ជឿ :	ច្រើន៤០០-៥០០នាក់ ជញ្ជូនដី ខ្លះគ្នាឡើងលើទំនប់ ឡើងមិនរួចដែលគ្នាស្គម គ្នាឡើងមិនរួចក៏ធ្លាក់មកក៏រួច ។

វណ្ណៈ :	អញ្ចឹងអ្នកមកពីភ្នំពេញក៏លើកទំនប់នោះដែរ?

ជឿ :	មកពីភ្នំពេញក៏លើក លើកទាំងអស់គ្នា ប្អូនភក្តីនៅភ្នំពេញដូចថាប្អូនវាមិនដែលចេះធ្វើប្អូនវានៅក្មេងមិនដែលចេះធ្វើ វាលើកទំនប់អត់រួច អ្នកនៅថា ឯង១អត់ធ្វើការ១ហៅគ្នាទៅវៃចោល ។

វណ្ណៈ :	អញ្ចឹងបើយើងអត់ទៅធ្វើការរួចគេហៅយើងទៅវៃចោល?

ជឿ :	ចាស! យើងអត់ទៅធ្វើការ យើងអត់ធ្វើការគេយកយើងទៅវៃចោលហើយ ។

វណ្ណៈ :	អញ្ចឹងសម័យនោះពេលដែលតាក្រកកាន់កាប់នោះក៏មានប្រជាជនស្លាប់ច្រើនដែរ?

ជឿ :	ស្លាប់ច្រើនសម័យនោះហើយ គេចេះតែវៃយើងបន្តបន្ទាប់ទាល់តែយួនឡើងវៃ ។

វណ្ណៈ :	បាទ១! អញ្ចឹងខ្ញុំចង់សួរពីអាងត្រពាំងថ្ម អញ្ចឹងអាងត្រពាំងថ្មទៅលើកទាំងយុវជន ទាំងយុវនារី?

ជឿ :	ចាស! ទៅទាំងអស់ ។

វណ្ណៈ :	អញ្ចឹងមានទាំងកសិករខ្លះទៀតចូលរួមដែរ អ្នកមានកូន?

ជឿ :	ទេយកតែយុវជន-នារី យកតែក្មេង១ ។

វ៉ន :	អាយុវ័យកណ្តាលអត់យកទេ

ជឿ :	វ័យកណ្តាលជម្រះចំការ ។

វណ្ណៈ :	ពេលទៅដល់នោះហូបចុកម៉េចដែរ?

ជឿ ៖ ទៅដល់នោះគេឲ្យបាយយើងហូបគ្រប់គ្រាន់ ទាស់តែកម្លាំងយើងសូរ(ខ្សោយ) បាយឲ្យស៊ីគ្រប់គ្រាន់គេដាំសុទ្ធតែបាយសាច់គោ ម្ហូបអាហារគេ ឲ្យតែយើងធ្វើការគេមិនឲ្យអត់សោះ បាយគេឲ្យមួយថ្ងៃ៣ដង ។

វណ្ណៈ ៖ អញ្ចឹងម៉េចមានប្រជាជនស្លាប់?

ជឿ ៖ ស្លាប់ដោយវាឈឺដែលលើកទំនប់ទៅ វាខ្ពស់លោកគ្រូមើលទៅស្រងំ ។

វណ្ណៈ ៖ អញ្ចឹងមានទឹកមានអី?

ជឿ ៖ មាន! មានទឹក គេដឹកទៅ អណ្តូងគេជីក មានដូចថា គ្នាធ្វើការរាល់ថ្ងៃវាសូរ(ខ្សោយ) ។

វណ្ណៈ ៖ វាសូរម៉េច?

វ៉ន ៖ (សើច) សូរៈ វាខ្សោយ អស់កម្លាំង ។

វណ្ណៈ ៖ អស់កម្លាំងគេហៅសូរ?

ជឿ ៖ ចាស! គេហៅសូរអញ្ចេះឯង (សើច) ។

វ៉ន ៖ អស់កម្លាំង ទន់ជើង ទន់ដៃ ។

វណ្ណៈ ៖ ខ្ញុំសួរគេ កន្លែងណានៅអាងត្រពាំងថ្មហូបចុកពិបាក ហើយទឹកនោះក៏ពិបាកដែរ ហើយមីងថាហូបពេលខ្ញុំ..?

ជឿ ៖ បាយគេឲ្យហូប៣ពេល។ គេដឹកទៅឲ្យគេលើកទៅសុទ្ធតែអាធុងធំដឹកទៅឲ្យ ខ្លាចវាមិនគ្រាន់អញ្ចឹងហើយចុះគ្នាច្រើនក្រែលមិនគ្រប់មិនគ្រាន់ ។

វ៉ន ៖ គេមានមុខព្រួញគេផ្សេង ។

ជឿ ៖ គេមានមុខព្រួញគេផ្សេង ។

វណ្ណៈ ៖ មានកន្លែងពិបាកអញ្ចឹង?

ជឿ ៖ គេមិនដែលឲ្យពិបាកទេបាយ ដាំសុទ្ធឆ្នាំងខ្ទះឲ្យយើងហូប ។

វ៉ន ៖ គេមានមុខព្រួញគេច្រើន ។

ជឿ ៖ បាយគេចែកឲ្យយើងណា ។

វណ្ណៈ ៖ អញ្ចឹងអ្នក១៧មេសាហូបឆ្អែតដែរ?

ជឿ ៖ ចាស?

វណ្ណៈ ៖ អ្នកដែលជម្លៀសមកពីភ្នំពេញបានហូបឆ្អែតដែរ?

វ៉ន ៖ អត់ឆ្អែតទេ ។

ជឿ ៖ អត់ឆ្អែតទេ ថាស៊ីសុទ្ធតែដំឡូង ដល់យើងអ្នកចាស់យើងចេះតែដាំធ្វើអី ដល់គ្នាអ្នកថ្មីមិនដាំធ្វើអីណុងគេគ្នាសម័យនោះបានអីហូប ថាស៊ីតែសំបកដំឡូងមីទេ ។

វណ្ណៈ ៖ អញ្ចឹងហូបតែសំបកដំឡូងមី តែមីងថាហូបពេលបាន៣ពេលនោះ?

ជឿ ៖ នោះទៅទំនប់ត្រពាំងថ្ម ។

វណ្ណៈ ៖ ទំនប់ត្រពាំងថ្មបានហូបឆ្អែតវិញ?

ជឿ ៖ បានហូបឆ្អែតឲ្យតែយើងដើតចល័តគេឲ្យហូបឆ្អែតហើយ ។

វណ្ណៈ ៖ មានគេយកទេវៃចោលអីទេ?

ជឿ ៖ មានវៃខ្លះយើង.... ខ្ញុំមិនដែលហ៊ានបៀតទេ គ្រាន់តែប្រធានហៅទៅ ខ្ញុំមិនដែលហ៊ានទៅជាន់ដង ។

វណ្ណៈ ៖ ចុះទៅដល់តំនប់ត្រពាំងទីនេះទៅមានចម្ងាយប៉ុន្មាន ពីភូមិយើងទៅមានចម្ងាយប៉ុន្មានគីឡូដែរ?

ជឿ ៖ ចាស?

វណ្ណៈ ៖ ពីនេះទៅត្រពាំងថ្មប៉ុន្មានដែរ?

ជឿ ៖ ឆ្ងាយណាស់មិនដឹងប៉ុន្មានគីឡូលោកគ្រូ នៅភ្នំស្រុកនោះ ស្គាល់ភូមិក្នុងស្រុកទេ?

វណ្ណៈ ៖ បាទៗ ។

ជឿ ៖ នៅភ្នំស្រុកនោះ ។

វណ្ណៈ ៖ កាលសម័យនោះអ្នកណានៅបញ្ជានៅអាងត្រពាំងថ្មនោះ?

ជឿ ៖ តាជន តាជន ធ្វើមេ ។

វណ្ណៈ ៖ ហើយអញ្ចឹងទំនប់នោះគេធ្វើធំប៉ុនណា ទំហំប៉ុន្មាន បណ្ដោយប៉ុន្មាន?

ជឿ ៖ ទទឹងធំហើយទំនប់ប៉ុនថ្នល់ជាតិនេះឯង ទំនប់ប៉ុនថ្នល់ជាតិ មិនបានវាស់ទេ មិនចែកជាវាស់ទេ ។

វណ្ណៈ ៖ បណ្ដោយឆ្ងាយ, អាអាងត្រពាំងថ្មនេះធ្វើទព្វ័ គេលើកធ្វើអ្វី?

ជឿ ៖ ធ្វើអី គេធ្វើស្រែប្រាំងធ្វើអីទៅណា ។

វណ្ណៈ ៖ ទប់ទឹក?

ជឿ ៖ ទប់ទឹកចាស ឲ្យតែយើងចេញធ្វើការបាយគេឲ្យស៊ីគ្រប់គ្រាន់ ។

វណ្ណៈ ៖ ទប់ទឹកសម្រាប់ធ្វើស្រែ?

ជឿ ៖ ចាស! ទប់ទឹកសម្រាប់ធ្វើស្រែ ។

វណ្ណៈ ៖ ហើយអាងនេះធ្វើហើយរួចរាល់?

ជឿ ៖ រួចហើយ! ធ្វើរួចហើយ ។

វណ្ណៈ ៖ មុននឹងធ្វើអាងណុងហើយ តើមនុស្សស្លាប់ប្រហែលជាប៉ុន្មានដែរ?

ជឿ ៖ ច្រើនណាស់ ប៉ះអ្នកណាខុសសីលធម៌គេយកទៅវៃចោល ។

វណ្ណៈ ៖ មានអ្នកខុសសីលធម៌ដែរ?

ជឿ ៖ មាន ។

វណ្ណៈ ៖ មីងមានស្គាល់ឈ្មោះទេ?

ជឿ ៖ មិនដែលស្គាល់ទេ ប៉ះអ្នកណាពស់ខាំគ្នាក៏ងាប់ទៅ ។

វណ្ណៈ ៖ មានពស់ខាំទៀត?

ជឿ ៖ មានពស់ច្រើនណាស់ ។

វណ្ណៈ ៖ ម៉េចបានពស់ព្រៃឬក៏យ៉ាងម៉េច?

ជឿ ៖ ព្រៃ! ព្រៃ ។

រ៉ែន ៖ ព្រៃឫស្សី

ជឿ ៖ ព្រៃឫស្សីល្វាចឡើងមិនហ៊ានចេញទេ គ្រាន់តែខាំអ្នកថ្មីពីរនាក់ ខាំពីរនាក់បងប្អូនគ្នាកូនអ្នកថ្មី ខ្ញុំស្រណោះណាស់ ខាំអាប្អូនងាប់អត់រកគ្រូឲ្យគ្នាទេ និយាយពីអាបងយំបោកខ្លួនលើផ្នូរប្អូន កប់នៅគៀនទំនប់នេះឯង និយាយពីអត់ទៅណាទេ និយាយពីនៅយំផ្នូរប្អូន ស្រណោះប្អូន ទៅពីនេះទៅតែពីរនាក់បងប្អូន គេវៃម៉ែឪចោលអស់មានតែពីរនាក់បងប្អូនប៉ុណ្ណោះ ទៅតែពីរនាក់បងប្អូនប៉ុណ្ណោះឯង ។

វណ្ណៈ ៖ អត់ស្គាល់ឈ្មោះទេ?

ជឿ ៖ អត់ស្គាល់ឈ្មោះទេ មានតែពីរនាក់បងប្អូនប៉ុណ្ណោះឯង គ្រាន់តែជួបគ្នា យើងឃើញគ្រាន់តែមើល សម្បុរណាស់ច្រើនតែពស់ប៉ុនៗនេះ ។ ខ្ញុំតែយប់ហើយមិនដែលហ៊ានចេញទេ ។

វណ្ណៈ ៖ អញ្ចឹងពេលស្លាប់ប្អូនហើយ បងស្លាប់ទៀតមិនមែន?

ជឿ ៖ អត់ទេ! កាលនោះក្រោយទៅទំនប់ក៏បែកគ្នា មិនដឹងស្លាប់រស់ទេ ត្រូវកូនអ្នកថ្មីដងស្អាតៗ មួយក៏ស្រណោះ ពីរក៏ស្រណោះគ្នា ។

វណ្ណៈ ៖ អញ្ចឹងក្នុងមួយថ្ងៃម្នាក់គេឲ្យលើកប៉ុន្មានម៉ែត្រគីប?

ជឿ ៖ លោកគ្រូអើយ ខ្ញុំភ្លេចបាត់ហើយ ប៉ុន្មានទេ ៣ម៉ែត្រគីប ។

វណ្ណៈ ៖ លើកហើយដែរ?

ជឿ ៖ លើកអត់ហើយ យប់ក៏ឲ្យទៅលើកទៀត មិនហើយស្អែកលើកទៀត ។

វណ្ណៈ ៖ អញ្ចឹងឲ្យលើកដល់ស្អែកទៀត មិនបានណាអី បើលើកមិនទាន់ឲ្យលើកដល់យប់ស្អើណាក៏ដោយ?

ជឿ ៖ ឲ្យចប់ ។

វណ្ណៈ ៖ ស្អែកវាស់ថ្មីទៀត?

ជឿ ៖ ស្អែកវាស់ថ្មីទៀត យប់ស្អើណាយប់ទៅគិតតែខំលើកឲ្យរួច ។

វណ្ណៈ ៖ បើយើងធ្វើមិនហើយក៏ស្លាប់ទៅ, អញ្ចឹងបានន័យថាអ្នកនៅអាងត្រពាំងថ្មមិនសូវមានស្គមមានអីទេ?

ជឿ ៖ អូរ! ស្គមណាស់លោកគ្រូអើយនៅសល់តែកដៃនេះ ប្អូនខ្ញុំដែលនៅរោងម៉ាស៊ីនឃើញតែកដៃ ។

វណ្ណៈ ៖ ចុះអឹថាមួយថ្ងៃបាយ៣ពេលនោះ?

ជឿ ៖ បើយើងធ្វើការសូរ ។

វណ្ណៈ ៖ ធ្វើការអស់កម្លាំង?

ជឿ ៖ ចាស! បើយើងធ្វើយប់ក៏ធ្វើថ្ងៃក៏ធ្វើ ។

វណ្ណៈ ៖ អញ្ចឹងមិនមែនវាឲ្យយើងហូបរហូត៣ពេល៣ឆ្នាំណា វាឲ្យហូបរហូតបុក៏បបរវិញ?

ជឿ ៖ បាយប៉ុណ្ណេះមួយចាន ប៉ុនគេឲ្យយើង៣ពេល ។

វណ្ណៈ ៖ មិនឆ្អែតទេអញ្ចឹង?

ជឿ ៖ ៣ពេល បើយើងស៊ីច្រើនម៉េចនឹងឆ្អែត បើមនុស្សប្រុសម៉េចនឹងឆ្អែត ។

វណ្ណៈ ៖ អញ្ចឹងឲ្យបាយរហូតបុក៏បបរពេលខ្លះ?

ជឿ ៖ ឲ្យបាយរហូតឲ្យតែធ្វើការនៅទំនប់ឲ្យបាយហើយ ប៉ុណ្ណេះឯងហើយបើអ្នកណាហូបច្រើនទៅម៉េចនឹងឆ្អែត បើអ្នកហូបតិចទៅឆ្អែត បើមានបងប្អូនអ្នកដាំបាយក៏ចេះឲ្យបងប្អូនយើងហូបទៅ ។

វណ្ណៈ ៖ មានដាំបាយផ្សេងទៀតបើគេ?

ជឿ ៖ ឆ្នាំងរួម ខ្ទះបាយរួម បើយើងហ៊ានតែទៅលួចអី វាឃើញវាវៃយើងចោលហើយស្រណោះគ្នាចង់ឲ្យបាយក្ដាំងបាយអីក៏មិនហ៊ានឲ្យដែរ ។

វណ្ណៈ ៖ ចុះដែលឃើញយាយថែមចុះទៅទេ?

ជឿ ៖ យាយថែមគាត់ចុះទៅម្ដងៗពេលធ្វើការហើយគាត់ទៅវិញហើយ ។

វណ្ណៈ ៖ មានហៅកងចល័តឡើងមកប្រជុំ?

ជឿ ៖ ហៅកងចល័តមកប្រជុំ ។

វណ្ណៈ ៖ ពេលប្រជុំគាត់មាននិយាយថាម៉េច?

ជឿ ៖ ប្រជុំឲ្យយើងដាច់ខាតវៃសម្រុក ។

វណ្ណៈ ៖ ឲ្យហើយអាងណុង?

ជឿ ៖ ឲ្យហើយអាងណុង ។

វណ្ណៈ ៖ ឲ្យហើយអាងណុងដើម្បីធ្វើអី?

ជឿ ៖ អាងនោះសម្រាប់គេទុកធ្វើស្រែប្រាំង ស្រែអីមានទឹកនៅសម្រាប់ស្រែប្រាំង ។

វណ្ណៈ ៖ ហើយអញ្ចឹងព្រលឹមឡើងម៉ោងប៉ុន្មាន?

ជឿ ៖ ព្រលឹមឡើងម៉ោង១១ ម៉ោង១ចុះ ។

វណ្ណៈ ៖ ម៉ោងប៉ុន្មានឈប់ទៀត?

ជឿ ៖ ម៉ោង៥ឡើង ។

វណ្ណៈ ៖ ចុះអាពេលធ្វើមនុស្សរាប់រយរាប់ពាន់នាក់អញ្ចឹង អ្នកណាអ្នកត្រួតពិនិត្យអាពេលធ្វើ?

ជឿ ៖ ធ្វើហ្នឹងប្រធានគេ តាជន មានដូចថា មួយក្រុម១០នាក់មានប្រធានគេមួយទៅគេដើរតាមក្រុម ។

វណ្ណៈ ៖ អញ្ចឹងមីងកាលនោះគេមានឲ្យកាន់ប្រធានក្រុមប្រធានអីគេដែរ?

ជឿ ៖ ទេ! អត់ទេ ។

វណ្ណៈ ៖ អញ្ចឹងប្រធានក្រុមមីងពីណាគេ?

ជឿ ៖ ភ្លេចហើយមិនដឹងអ្នកណាគេទេលោកគ្រូប្រធានក្រុមដល់វាយូរពេក មួយក្រុម១០នាក់ចេះតែនាំគ្នាធ្វើការទៅ ។

វណ្ណៈ ៖ អញ្ចឹងយាយថែមធ្លាប់មកជួបតាក្រុកដែរ?

ជឿ ៖ មក ។

វណ្ណៈ ៖ ចុះពេលចាប់តាក្រុកទៅ តើមីងដឹងថាពីណាអ្នកចាប់ទេ ខាងយាយថែមចាប់ឬខាងពីណា?

ជឿ ៖ ខ្ញុំអត់ដឹងដែរស្រាប់តែបាត់ខ្លួនតាក្រុក ។

វណ្ណៈ ៖ ឆ្នាំណាបាត់ខ្លួនតាក្រុក?

ជឿ ៖ ឆ្នាំណា? យួនជិតចូល ។

វណ្ណៈ ៖ អញ្ចឹង៧៨បាត់ខ្លួនតាក្រុក?

ជឿ ៖ បាត់តាក្រក បាត់តាហ៊ីន ប្រធានឲ្យតែពួកនិរតីចូលបាត់ ។

វណ្ណៈ ៖ តាអីមួយទៀត តាហ៊ុន តាហ៊ីង?

ជឿ ៖ តាហ៊ុន ។

វណ្ណៈ ៖ តាហ៊ីន?

ជឿ ៖ ចាស ។

វណ្ណៈ ៖ តាជនខាងនិរតីទេ ខាងជាមួយយាយថែម?

ជឿ ៖ ចាស! តាជនខាងនិរតីឃុំហើយ តាក្រកប្រធាន បងជននេះអនុ ។

វណ្ណៈ ៖ អនុ! ពេលចាប់តាក្រកទៅគាត់ឡើង?

ជឿ ៖ គាត់ចេះតែផ្ញើគាត់ខ្លាចខ្លួនគាត់ដែរ គេចាប់គាត់ ។

វណ្ណៈ ៖ ពីណា?

ជឿ ៖ តាជន គាត់ខ្លាចខ្លួនខ្លាចគេចាប់ខ្លួនទៅដែរ ខ្លាចគេចាប់គាត់ទៅវៃចោល គាត់ខ្លាចដូចតែគ្នា នេះស្រេចតែបញ្ជាពីថ្នាក់លើមក គាត់ខ្លាចដែរ ។

វណ្ណៈ ៖ អញ្ចឹងការងារទាំងអស់នេះទាក់ទងបញ្ជាពីឡើងមកទេ?

ជឿ ៖ ចាស! បញ្ជាពីលើមក ។

វណ្ណៈ ៖ អញ្ចឹងមិនមែនអាក្រោមចេះតែចាប់ទេ?

ជឿ ៖ មិនមែន ។

វណ្ណៈ ៖ ចុះមីងម៉េចដឹងថាមកពីលើ?

ជឿ ៖ ចុះប្រធានឲ្យតែមានគេមានបញ្ជាពីលើមក កូនចៅនៅនេះដូចថា កូនចៅ ។

វណ្ណៈ ៖ កាលនោះអត់មានស្គាល់តាញឹម តា រស់ ញឹម តាអីទេ?

ជឿ ៖ អត់ដែលស្គាល់ទេ ។

វណ្ណៈ ៖ ស្គាលយាយថែមស្គាល់មិនសូវច្បាស់ផង?

ជឿ ៖ មិនសូវច្បាស់ផង អាល័យតែធ្វើការមានបានត្រូតឯណា ។

វណ្ណៈ ៖ ចុះសម័យយាយថែម សម័យតាក្រកមួយណាស្រួលជាង?

ជឿ ៖ យាយថែមគាត់នៅ គាត់មិនដែលមកនៅនេះទេ គ្រាន់តែវេលាធ្វើការធំៗគាត់ចុះមកធ្វើ ។

វណ្ណៈ ៖ អញ្ចឹងកាលសម័យតាក្រកស្លាប់មនុស្សច្រើនទេ?

ជឿ ៖ មនុស្សច្រើន ។

វណ្ណៈ ៖ ចុះសម័យយាយថែមស្លាប់មនុស្សច្រើនទេ?

ជឿ ៖ ទេ! យាយថែម តាក្រុក នៅជុំគ្នា ។

វណ្ណៈ ៖ ប៉ុនគេចាប់តាក្រុកទៅបាត់នៅសល់យាយថែមនេះ?

ជឿ ៖ នៅតាផន ។

វណ្ណៈ ៖ តាផន និង យាយថែម ស្លាប់មនុស្សច្រើនទេ?

ជឿ ៖ ស្លាប់ប្រជាជនច្រើនដែរ ពួកទាហាន ស្លាប់តែពួកទាហានទេ ដូចប្រជាជនយើងស្លាប់ៗ ដោយសារអត់ចំណីអាហារ ស្លាប់ដូចថាទាហាន ។

វណ្ណៈ ៖ អញ្ចឹងបងប្អូនមីងអត់មានស្លាប់ក្នុងសម័យនោះទេ?

ជឿ ៖ ទាស់តែម្ដាយមីងខ្ញុំងាប់ទាស់ធ្វើការរោងចក្រអស់មួយគ្រួសារនៅសល់តែកូនមួយគត់ ។

វណ្ណៈ ៖ រោងចក្រណា?

ជឿ ៖ រោងចក្របាត់ដំបង អាខាងលិច គេហៅអីវាលបាត់ដំបង ។

វណ្ណៈ ៖ ម៉េចបានស្លាប់មានដឹងទេ?

ជឿ ៖ ស្លាប់អី វាយកទៅវៃចោលអស់មួយគ្រួសារ ។

វណ្ណៈ ៖ នោះគាត់ចូលទៅបម្រើខាងខ្មែរក្រហម ធ្វើរោងចក្រ?

ជឿ ៖ នោះឯង ។

វណ្ណៈ ៖ យកទាំងប្ដីទាំងកូន?

ជឿ ៖ កូនប៉ុន្មាន ទាំងប្ដីទាំងអីទាំងអស់ នៅសល់តែមីកូនមួយ គ្មានពិបាកវេទនាណាស់ ។

វណ្ណៈ ៖ អញ្ចឹងសល់កូនមួយរាល់ថ្ងៃ?

ជឿ ៖ សល់កូនមួយ ។

វណ្ណៈ ៖ ត្រូវជាយ៉ាងម៉េចមីង?

ជឿ ៖ ត្រូវជាបងប្អូនជីដូនមួយ ។

វណ្ណៈ ៖ ឈ្មោះអីទៅ?

ជឿ ៖ ម៉ែវាម៉ែខ្ញុំបងប្អូនបង្កើត ។

វណ្ណៈ ៖ បាទ! អ្នកស្លាប់ដែលស្លាប់មួយគ្រួសារនោះឈ្មោះអី?

ជឿ ៖ ឈ្មោះ ពុំន, ឈួន ។

វណ្ណៈ ៖ ឈួន?

ជឿ ៖ ចាស! កូន ជ័យរៀក ចាន់រីក ចាន់ណាង នៅតែរម្ចីមួយទេ នៅតែមួយទេអស់មួយគ្រួសារ ។

វណ្ណៈ : ឈ្មួននោះប្ដីពើន?

ជឿ : ប្ដីរឿន

វណ្ណៈ : ប្ដីរឿន?

ជឿ : ចាស ។

វណ្ណៈ : ហើយកូនប៉ុន្មាននាក់ស្លាប់ ។

ជឿ : កូន៤ស្លាប់ មើល ជ័យរឿក ចាន់នី ចាន់ណាង កូន៣-៤នៅសល់មួយ ។

វណ្ណៈ : កូនមួយម៉េចបានសំណាងនៅរស់?

ជឿ : នៅគេ ដល់ពេលនេះបានគេយកទៅចិញ្ចឹម អ្នកសៀមរាបយកទៅចិញ្ចឹម ចិញ្ចឹមទាល់តែធំ ជិតបានប្ដីហើយបានស្រាវជ្រាវរកបងប្អូននៅនេះបានដឹង ។

វណ្ណៈ : ប៉ុន្ដែគាត់ទៅរោងចក្រនៅខាងបាត់ដំបងទាំងអស់គ្នាមួយរោងចក្រ?

ជឿ : ទាំងអស់មួយគ្រួសារ ។

វណ្ណៈ : អញ្ចឹងប្រហែលមួយនោះគេសុំចេញមក សុំយកចិញ្ចឹម?

ជឿ : គេសុំយកចិញ្ចឹមនោះឯង ។

វណ្ណៈ : បើនៅជុំគ្នាស្លាប់ទាំងអស់?

ជឿ : ស្លាប់ទាំងអស់ ។

វណ្ណៈ : អ្នកនៅរស់ឈ្មោះអី?

ជឿ : ឈ្មោះ រម្ទី ។

វណ្ណៈ : រម្ទី?

ជឿ : ចាស! ក្ដីប រម្ទី ។

វណ្ណៈ : អញ្ចឹងមានសាច់ញាតិស្លាប់នៅក្នុងសម័យខ្មែរក្រហមគេយកទៅវៃចោល?

ជឿ : អត់មាន មានតែមួយគ្រួសារនេះឯង ។

វណ្ណៈ : មានអ្នកស្រុកអ្នកភូមិស្លាប់ដោយអត់បាយទៀត?

ជឿ : អត់មានទេ នេះយើងចេះតែរកទៅណា មានស្លាប់អត់បាយទេ ចេះតែរកចេះតែស៊ីគល់ចេកគល់អីទៅណា ដាក់មោងដាក់អី លួចបូតស្រូវបូតអីខ្លះ ធ្វើខ្លួនឯងបូតខ្លួនឯង ចេះតែបានហើយយើងក៏បបរស៊ីទៅ ។

វណ្ណៈ : ហើយនៅព្រះនេត្រព្រះនេះ កាលនោះគេហៅតំបន់ប៉ុន្មាន?

ជឿ ៖ តំបន់៥ នេះតំបន់៥គេហៅវេហាលខ្លាំង បើស្រុកក្រោមតំបន់៣គេមិនសូវហៅវេហាលទេស៊ីរហូត ខ្លាំងតែតំបន់៥នេះហើយ ។

វណ្ណៈ ៖ នៅក្នុងខេត្តបាត់ដំបងមានប៉ុន្មានតំបន់ មីងមានដឹងថាមានតំបន់ណាខ្លះ?

ជឿ ៖ មិនដឹង ។

វណ្ណៈ ៖ អត់ដឹងដែរ?

ជឿ ៖ ខ្ញុំមិនដឹងដែរ មិនដឹងបែងចែកប៉ុន្មានដែរ ។

វណ្ណៈ ៖ ពួកនិរតីរត់ទៅខាងណា?

ជឿ ៖ ទៅព្រៃដើង នាំគ្នាបរទេសទៅអស់អត់ហ៊ាននៅ អត់ហ៊ានខ្លាចប្រជាជនវៃសម្លាប់ ព្រោះតែឃួនវៃ ក្តីង១មកវានាំគ្នារត់អស់ វាដែលហ៊ានហា ។

វណ្ណៈ ៖ ប្រជាជនវៃអត់ទាន់?

ជឿ ៖ វៃអត់ទាន់ បើសិនថានៅឯងសម្លាប់ ។

វណ្ណៈ ៖ ប្រជាជនខឹងពេកហា?

ជឿ ៖ ចាស ។

វណ្ណៈ ៖ ដល់ពេល៧៩វៀតណាមចូលមកមីងរស់នៅក្នុងភូមិនេះដដែលទៅ?

ជឿ ៖ ចាស! នៅភូមិនេះឯង ។

វណ្ណៈ ៖ នៅទៅប្រកបមុខរបរអីទៅពី៧៩មក?

ជឿ ៖ ខ្ញុំឡើងត្នោតធ្វើស្រែ ។

វណ្ណៈ ៖ មីងឡើងត្នោតរួចដែរ?

ជឿ ៖ ទេ! ប្តីខ្ញុំឡើង ។

វណ្ណៈ ៖ មីងដូចថានៅផ្ទះរំងាស់ស្ករអញ្ចឹងទៅ?

ជឿ ៖ ចាស ។

វណ្ណៈ ៖ មកដល់សព្វថ្ងៃធ្វើអីទៀត នៅតែឡើងត្នោតរហូត?

ជឿ ៖ នៅតែឡើងត្នោត ។

វណ្ណៈ ៖ បានកូនចៅអីទៅរៀនទៅសូត្រអីបានច្រើនដែរឬរៀបការអស់ហើយ?

ជឿ ៖ ពីរនាក់ទៅថៃអស់ហើយលោកគ្រូ ។

វណ្ណៈ ៖ អូរ! បានពីរនាក់ទៅថៃដែរ?

ជឿ ៖ ចាស ។

វណ្ណៈ : ខស្សរាហ័ផ្ញើសំបុត្រទាក់ទងដែរ?

ជឿ : អាមួយអាបង១៣ឆ្នាំហើយ មិនដែលឮដំណឹងដំណូចផង ដឹងតែអាប្អូន ។

វណ្ណៈ : អញ្ចឹងដូចថាមកដល់ថ្មីៗនេះមានតុលាការកាត់ទោស មីងមានស្តាប់មានដឹងទេ?

ជឿ : ខ្ញុំអត់មានដឹង ។

វណ្ណៈ : តុលាការកំពុងតែកាត់ទោសអ្នកដែលធ្វើបាបប្រជាជនក្នុងសម័យនោះ តើមីងគិតយ៉ាងម៉េច ដែរថា មានកាត់ទោសអញ្ចឹងល្អឬក៏មិនល្អទេ ឬក៏គួរតែលេងគាត់ទៅក៏យ៉ាងម៉េច?

ជឿ : ស្រេចតែប្រជាជន ។

វណ្ណៈ : មីងក៏ប្រជាជនមួយដែរ មានសិទ្ធិនិយាយថាយ៉ាងម៉េចៗអញ្ចឹង ព្រោះកាលមុនកាត់ទោសនេះគេសំដៅទៅលើអ្នកដឹកនាំកំពូល គាត់បានកាន់កាប់អំណាចធ្វើឲ្យប្រជាជនស្លាប់ជិត១លាននាក់ ។ សព្វថ្ងៃនេះមាន តាអៀង សារី, តាខៀវ សំផន, នួន ជា និង ប្រពន្ធអៀង សារី លោកស្រី អៀង ធីរិទ្ធិ ហើយឌុចគេកាត់ក្តីហើយ អញ្ចឹងនៅសល់៤នាក់នេះគេនឹងកាត់ក្តីក្នុងឆ្នាំហ្នឹង តើមីងគិតថាកាត់ក្តីនេះជាការត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេ?

ជឿ : មិនដឹងផងលោកគ្រូ ។

វណ្ណៈ : អត់ដឹងទេ?

ជឿ : ចាស ។

វណ្ណៈ : អញ្ចឹងអ្នកដឹកនាំដែលធ្វើបាបមីងមកដល់សព្វថ្ងៃនេះមីងអត់ខឹងទេ?

ជឿ : ខឹងអី ស្រេចតែទិសគេ ។

វណ្ណៈ : មីងអត់ខឹង?

ជឿ : ខឹងដែរ ដែលវៃម្តាយមីងគ្រួសារខឹងហើយ បើគ្នាខុសអី គ្នាធ្វើតែកម្មកររោងចក្រគេ បើសិនថា វៃប្តីគាត់ ទុកកូនទៅ បើវៃម៉ែឪ ទុកកូនទៅ នេះវៃគ្នាអស់មួយគ្រួសារ កូនគ្នានៅតែមួយ ។

វណ្ណៈ : ចុះអ្នកស្រុកអ្នកភូមិនេះក្រៅពីឡើងត្នោតមានប្រកបមុខរបរអី?

ជឿ : ធ្វើស្រែ ដាំបន្លែ ។

វណ្ណៈ : មានបន្លែអីខ្លះ?

ជឿ : មានត្រកួនលក់ទៅ ត្រសក់ទៅ មុខរបរអ្នកស្រែ ធ្វើអានេះតិចទៅ ។

វណ្ណៈ : បើប្រៀបធៀបកាលសម័យខ្មែរក្រហម និង សម័យឥឡូវ មួយណាស្រួលជាង?

ជឿ ៖ សម័យនេះហើយស្រួល សេរី ។
វណ្ណៈ ៖ សេរី?
ជឿ ៖ (សើច) សេរី ។
វណ្ណៈ ៖ លែងលើកទំនប់?
ជឿ ៖ ចាស! លែងពិបាកភ័យភិតអី ។
វណ្ណៈ ៖ កាលមីងលើកទំនប់បានរៀបការឬក៏រៀបការហើយបានលើកទំនប់?
ជឿ ៖ នេះកំពុងលើកនេះឯង គេបើកវគ្គ ។
វណ្ណៈ ៖ មីងរៀបការប៉ុន្មានគូ?
ជឿ ៖ កាលនេះ២៥គូ ។
វណ្ណៈ ៖ ពេលដែលការហើយគេឲ្យមកភូមិវិញ គេលែងឲ្យនៅហើយ?
ជឿ ៖ បើកវគ្គ អ្នកដែលការគេលេងឲ្យទៅគំទប់ត្រពាំងថ្មទៀតហើយ ឈប់ឲ្យទៅហើយ យើងកើតវ័យកណ្ដាលដូចថា យើងធ្វើការនៅភូមិស្ទួងស្រូវស្ទួងអីទៅ ធ្វើការនៅនារីក៏ដើរៗ ទៅ ប៉ះកន្លែងគេស្មើក៏យកទៅ វាសង្កា ទៅលើកទំនប់ឡើងពីរបីស្ទួង សូរ(អស់កម្លាំង) ធំតែក្បាលកដៃប៉ុនវែក ។
វណ្ណៈ ៖ អញ្ចឹងមីងខ្ញុំដូចអស់អីសួរមីងហើយ សូមអរគុណច្រើន ។
ជឿ ៖ ចាស! អរគុណហើយ ។

«ចប់»